# គណបក្ស សិទ្ធិមនុស្ស

## HUMAN RIGHTS PARTY

បំរើ ការពារ កសាង

**កើតពីប្រជាពលរដ្ឋ របស់ប្រជាពលរដ្ឋ ដើម្បីប្រជាពលរដ្ឋ**

*ព្រឹត្តិប័ត្រព័ត៌មានប្រចាំសប្តាហ៍* *ថ្ងៃសុក្រ ទី០៥ ខែមិថុនា ឆ្នាំ២០០៩* *ព្រឹត្តិប័ត្រលេខ៨៧ ឆ្នាំទី២*



| មាតិកាព័ត៌មាន | ទំព័រ |
|---|---|
| -ប្រជាពលរដ្ឋនៅខេត្តរតនៈគីរីដង្ហែរក្បួនតវ៉ានឹងឈ្មួញលួចកាប់បំផ្លាញព្រៃឈើ | ១ |
| -សមាគមខ្មែរកម្ពុជាក្រោមប្រារព្ធខួបលើកទី៦០ | ២ |
| -ប្រជាពលរដ្ឋជាង១០០គ្រួសាររកំពុងរងគ្រោះពីបញ្ហាដីធ្លីនៅខេត្តស្វាយរៀង | ៣ |


## ប្រជាពលរដ្ឋនៅខេត្តរតនៈគីរីដង្ហែរក្បួនតវ៉ានឹងឈ្មួញលួចកាប់បំផ្លាញព្រៃឈើ

លោក **ប៉ែន ប៊ុណ្ណា** អ្នកសំរបសំរួលសមាគមអាដហុកការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជាដែលមានមូលដ្ឋាននៅខេត្តរតនៈគីរីបានថ្លែងថា កាលពីព្រឹកថ្ងៃទី០១ ខែមិថុនានេះថា បើនៅតែមានការកាប់រានដីព្រៃ ការរំលោភសិទ្ធិមនុស្ស និងការកាប់ឈើខុសច្បាប់ យើងនឹងនៅតែដង្ហែរក្បួនប្រឆាំងតវ៉ាជាបន្តទៀត ។

លោក **ប៉ែន ប៊ុណ្ណា** បានបញ្ជាក់បន្ថែមទៀតថា បើធៀបបទល្មើសការកាប់បំផ្លាញព្រៃឈើ ការរំលោភបំពានដីធ្លីរបស់ជនជាតិដើមភាគតិចនាឆ្នាំ២០០៩ នេះទៅនឹងឆ្នាំ២០០៨ កន្លងទៅឃើញថា បទល្មើសទាំងនោះមានការថយចុះ ។ ទោះបីយ៉ាងនេះក្តីលោក **ប៉ែន ប៊ុណ្ណា** បានចាត់ទុកថាអ្នកប្រព្រឹត្តបទល្មើសព្រៃឈើ គឺជាបទល្មើសឧក្រិដ្ឋ គេមិនអាចដកហូតយកដីវិញ ហើយអ្នកប្រព្រឹត្តបទល្មើសទាំងអស់ និងអ្នកពាក់ព័ន្ធទទួលទោសតាមច្បាប់ ។

តំណាងសហគមន៍ជនជាតិទំពួន នៅស្រុកបរកែវ ខេត្តរតនៈគីរីបានឱ្យដឹងថា សហគមន៍ជនជាតិដើមភាគតិចសប្បាយចិត្ត និងចូលរួមក្បួនដង្ហែរ ដែលរៀបចំឡើងដោយសមាគមអាដហុក និងអង្គការសង្គមស៊ីវិលដទៃទៀត ។ ការសំរេចចិត្តចូលរួមក្នុងការដង្ហែរក្បួនក្នុងកំឡុងខែមិថុនានេះ គឺក្នុងគោលបំណងប្រឆាំងទៅនឹងការរំលោភបំពានដីធ្លី និងការកាប់បំផ្លាញព្រៃឈើនៅតែកើតមាន ។ អញ្ចឹងហើយបានជាជនជាតិភាគតិចមានការព្រួយបារម្ភខ្លាចក្រែង ដីធ្លីវិលជុំរបស់ពួកគាត់បាត់បង់ព្រៃឈើរលត់រលាយ ពីព្រោះជនជាតិរបស់លោកល្វិតល្វង់ក្រីក្រហើយសព្វថ្ងៃនេះមានតែសំរក់ទឹកភ្នែកប៉ុណ្ណោះ ។ លោកបានស្តីបន្ទោសទៅលើប្រមុខរដ្ឋាភិបាល គឺលោកនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ថាមិនបានចុះទៅអន្តរាគមន៍ជួយពួកគាត់ ។

លោក **ប៉ែន សុវណ្ណ** ប្រធានគណៈកម្មាធិការវិន័យរបស់គណបក្សសិទ្ធិមនុស្ស មានប្រសាសន៍ថាកាលពីទសវត្សឆ្នាំ១៩៨០ ។ ធម្មជាតិនៅខេត្តរតនៈគីរីមានទិដ្ឋភាព សោភណ្ឌភាពស្រស់បំព្រង

គួរឱ្យមោទន ប៉ុន្តែបច្ចុប្បន្ននេះមានភាពអាណាធិបតេយ្យឱ្យអ្នកមានអំណាចឧកញ៉ាកាប់បំផ្លាញព្រៃឈើរំលោភបំពានដីធ្លី ។ លោកអាណិតអាសូរជនជាតិដើមភាគតិច ដោយសារលោកមិនមានសិទ្ធិអំណាចក្នុងការតវ៉ា ។

តំណាងសហគមន៍ជនជាតិទំពួន នៅស្រុកបរកែវបាន បង្ហើបប្រាប់ថា ជនជាតិទំពួន ចារាយ ព្រៅ ការ៉ែន ការចក់ នៅឃុំញ៉ាង ស្រុកអណ្តូងមាស ខេត្តរតនៈគីរី គ្រោងនឹងធ្វើចំណាកស្រុកទៅរស់នៅទឹកដីយួន និងលាវប្រសិនបើអាជ្ញាធរព្រងើយកន្តើយមិនដោះស្រាយទុក្ខកង្វល់សហគមន៍ជនជាតិដើម និងក្រុមហ៊ុននៅតែបន្តឈូសឆាយដីធ្លីជនជាតិដើមទៀតនោះ ។

## សមាគមខ្មែរកម្ពុជាក្រោម ប្រារព្ធខួបលើកទី៦០

លោក **ស៊ឹន សូប៊ែរ្ត៍** ប្រធានគណៈកម្មាធិការនាយករបស់គណបក្សសិទ្ធិមនុស្ស និងជាក្រុមប្រឹក្សាធម្មនុញ្ញ បានថ្លែងសុន្ទរកថានៅក្នុងទិវារំឭកខួប៦០ឆ្នាំ ដែលរៀបចំឡើងដោយសមាគមខ្មែរកម្ពុជាក្រោមថា ថ្ងៃនេះក៏ដូចជាបណ្ដាឆ្នាំមុនៗដែរ សមាគមន៍ខ្មែរកម្ពុជាក្រោម បានប្រារព្ធខួបថ្ងៃដែលប្រជាពលរដ្ឋខ្មែរត្រូវបានពួកអាណានិគម បំពានសិទ្ធិសេរីភាពទាំងកំរោល ដោយបានកាត់ទឹកដីដូនតារបស់យើង ឱ្យទៅអាជ្ញាធរ**អាណ្ណាម**យួនក្រោមអធិរាជកៅដាយ ដោយគ្មានសួរនាំមតិពីម្ចាស់ស្រុក ។

លោក **ស៊ឹន សូប៊ែរ្ត៍** ជាបុត្រារបស់សម្ដេចបវរសេដ្ឋា **ស៊ឹន សាន** និងជាចៅទួតលោកឧកញ៉ា **ស៊ឹន គុយ** វិរៈបុរស ខ្មែរកម្ពុជាក្រោមបានថ្លែងទៀតថា ថ្ងៃនេះក៏ជាព្រឹត្តិការណ៍មួយប្រាប់ទៅពិភពលោក និងសហគមន៍អន្តរជាតិ ថាប្រជាពលរដ្ឋខ្មែរនៅតែមិនអស់ចិត្តនឹងសោកស្ដាយទឹកដីដូនតារបស់ខ្លួន និងបដិសេធដាច់ខាតនូវរាល់ទង្វើរបស់ពួកបារាំងសេស ដែលប្រើសិទ្ធិអាណានិគមផ្ដាច់ការ កាត់យកទឹកដីដូនតារបស់យើងឱ្យទៅអាជ្ញាធរ**អាណ្ណាមកៅដាយ** គ្រប់គ្រងដោយគ្មានឆ្លងកាត់ការធ្វើប្រជាមតិពីប្រជាពលរដ្ឋខ្មែរក្រោម ។

លោក **ស៊ឹន សូប៊ែរ្ត៍** ក៏បានស្នើឱ្យសហគមន៍អន្តរជាតិជួយគាំទ្រ និងផ្ដល់យុត្តិធម៌ដល់ខ្មែរកម្ពុជាក្រោមព្រមទាំងការពារទឹកដីកម្ពុជាក្រោមដែលត្រូវអាជ្ញាធរយួនរំលោភបំពាន ។

លោក **សុន ឆ័យ** សមាជិករដ្ឋសភាគណបក្សសម រង្ស៊ី មានប្រសាសន៍ថា បងប្អូនខ្មែរក្រោមថា ជាជាតិសាសន៍មួយមានស្មារតីតស៊ូស្វិតស្វាញ ជំរុញឱ្យមានការរស់រានមានជីវិតរហូតមកដល់សព្វថ្ងៃនេះ ។ ជាបទពិសោធន៍បានបង្ហាញឱ្យឃើញថា បើខ្មែរបែកបាក់គ្នាជាតិយើងនឹងបាត់បង់ទឹកដី បើខ្មែរមិនស្រលាញ់ជាតិរបស់ខ្លួន ខ្មែរនឹងត្រូវបរទេសឈ្លានពាន ធ្វើទុក្ខទោសរបួសជាតិរបស់យើង ។

លោក **សុន ឆ័យ** បានគូសបញ្ជាក់ទៀតថា គណបក្ស សម រង្ស៊ី នឹងស្នើឱ្យយកថ្ងៃទី០៤ ខែមិថុនា ជាថ្ងៃរំឭកខួបធ្វើជាថ្ងៃបុណ្យជាតិ ។ លោក **សុន ឆ័យ** ក៏ធ្លាប់បានធ្វើទស្សនៈកិច្ចជាផ្លូវការទៅកាន់ទឹកដីកម្ពុជាក្រោម ជាពិសេសនៅខេត្ត **ឃ្លាំង** និង **ព្រះត្រពាំង** ហើយលោកក៏បានសាកសួរបងប្អូននៅទីនេះ ដោយទទួលពតិមានថា ការធ្វើទុក្ខទោសម្ទេញ រំលោភបំពានយកដីធ្លី បំបិទសិទ្ធិសេរីភាព ជំនឿសាសនា និងការគំរាមកំហែងសព្វបែបយ៉ាងពីសំណាក់អាជ្ញាធរនៅទីនោះ ។

លោក **សុន ឆ័យ** បានបន្តទៀតថា ប្រជាជាតិជាជនជាតិមួយដែលមិនអាចបំផ្លិចបំផ្លាញតាមអំពើចិត្តបានទេ ។ ប្រជាពលរដ្ឋខ្មែរគ្រប់រូបទោះនៅទីណាក៏ដោយ ត្រូវទទួលបានការគាំពារពីរដ្ឋ ។ លោកបានថ្លែងទៀតថា ជនជាតិយួននៅកម្ពុជាមានសិទ្ធិបង្កើតសមាគមបាន ចុះហេតុអ្វីបានបងប្អូនខ្មែរក្រោមមិនមានសិទ្ធិបង្កើតសមាគមនៅកម្ពុជាក្រោម ។ ដូច្នេះអាជ្ញាធរយួនត្រូវតែផ្ដល់សិទ្ធិត្រឹមត្រូវដល់បងប្អូនខ្មែរកម្ពុជាក្រោម ។

# ប្រជាពលរដ្ឋជាង១០០គ្រួសាររងគ្រោះពីបញ្ហាដីធ្លីនៅខេត្តស្វាយរៀង

ប្រជាពលរដ្ឋ១០៩គ្រួសារនៅភូមិជីកដី ឃុំអណ្តូងត្របែក ស្រុករមាសហែក ខេត្តស្វាយរៀង បានអះអាងថា អាជ្ញាធររដ្ឋបាលព្រៃឈើបានយកដីធ្លីរបស់ពួកគាត់ ដែលបានកាន់កាប់តាំងពីឆ្នាំ១៩៧៩ ចំនួន៧១ហិកតាដាំកូនឈើលើ ដីគាត់ប្រកបរបរកសិកម្មរាល់ថ្ងៃ ។

តំណាងប្រជាពលរដ្ឋនៅភូមិជីកដី បានលើកឡើងថា កាលពីឆ្នាំ ១៩៧៩ ប្រជាពលរដ្ឋបានកាន់កាប់លុះដល់ឆ្នាំ ១៩៩១ អាជ្ញាធរបានដាំកូនឈើម្តងរួចហើយ ។ ប៉ុន្តែនៅឆ្នាំ ២០០១ កូនឈើដែលដាំនោះវារេចរិល ដូច្នេះហើយអ្នកភូមិជីកដី ក៏បានកាន់កាប់ដីទំនាស់នោះម្តងទៀតចាប់ពីឆ្នាំ២០០១-២០០៨ ឥឡូវនេះខាងរដ្ឋបាលព្រៃឈើបានដាំកូនឈើនៅលើដីនោះ កាលពីឆ្នាំ២០០៨ ដោយដាំលើសំណាបសន្ទូងរបស់ប្រជាកសិករ ។

តំណាងអ្នកភូមិជីកដីបានបន្តទៀតថា ដីស្ថិតក្នុងសភាពប្រទូស្តរ៉ាយនោះត្រូវបានអាជ្ញាធរមានសមត្ថកិច្ចលបលក់ឱ្យ ឧកញ៉ាម្នាក់បាត់ទៅហើយ ដោយគេគ្រាន់តែដាំកូនឈើដើម្បីបំភាន់បំភ្លៃប្រជាពលរដ្ឋតែប៉ុណ្ណោះ ។

លោក **អ៊ូ ច័ន្ទឫទ្ធិ** អ្នកតំណាងរាស្ត្រមណ្ឌលកណ្តាលរបស់គណបក្សសិទ្ធិមនុស្ស មានប្រសាសន៍ពីទឹកដីភូមិជីកដី ឃុំអណ្តូងត្របែកថា ប្រសិនបើជារបស់រដ្ឋមែននោះ ម្តេចក៏មានទាហ៊ានយាមកាមហើយឥឡូវប្រជាពលរដ្ឋ មិនអាចដើរឆ្លងកាត់បានទេ ។

លោក **អ៊ូ ច័ន្ទឫទ្ធិ** គូសបញ្ជាក់ទៀតថា បច្ចុប្បន្ននេះប្រជាពលរដ្ឋគ្មានអំណាចហើយមានជីវភាពក្រីក្រ ។ យើងថាជំលោះដីធ្លីច្រើនកើតឡើងរវាងប្រជាពលរដ្ឋក្រីក្រ ជាមួយអ្នកមានអំណាច ចំណែកប្រជាពលរដ្ឋក្រីក្រច្រើនតែរងគ្រោះ ។ ជាមួយគ្នានេះអ្នកតំណាងរាស្ត្រគណបក្សសិទ្ធិមនុស្ស ក៏បានស្នើឱ្យប្រមុខរដ្ឋាភិបាលជួយដោះស្រាយជូនប្រជាពលរដ្ឋ ដើម្បីបញ្ចប់បញ្ហា ពីព្រោះលោកយល់ថា នៅទីនោះកើតមានបញ្ហាដីធ្លីនៅកន្លែងផ្សេងទៀតក៏កើតមានបញ្ហាដូចគ្នាផងដែរ ។

លោកអាចារ្យនៅវត្តជីកដី ឃុំអណ្តូងត្របែកមានប្រសាសន៍ថា រដ្ឋបាលព្រៃឈើគេថាជាដីរបស់រដ្ឋ ហើយក៏បានដាំកូនឈើនៅលើដីស្រែចំការដែលបងប្អូនធ្លាប់ធ្វើនាឆ្នាំ១៩៧៩ ហើយដីនោះក៏ជាដីរបស់ប្រជាពលរដ្ឋតាំងពីដូនតាមកម្ល៉េះ ។ លោកអាចារ្យបានបន្តថា បញ្ហាទំនាស់ដីធ្លីកើតមានការរំដើបរំជួសទូទាំងប្រទេសមិនមែនកើតឡើងតែនៅភូមិរបស់គាត់ប៉ុណ្ណោះ ។

លោក **ឡុង ហ៊ុន** មេឃុំអណ្តូងត្របែក បានបញ្ជាក់ថា ដីនោះស្ថិតក្នុងរង្វង់រដ្ឋបាលព្រៃឈើ ប៉ុន្តែកាលពីឆ្នាំទៅមិញ រដ្ឋបាលព្រៃឈើបានដាំកូនឈើឡើងវិញ ។

ក្រោយពីឆ្នាំ១៩៨០ ប្រជាពលរដ្ឋនៅភូមិជីកដី ឃើញដីទំនេរពួកគាត់ក៏នាំគ្នារាតភ្ជួរស្ទូង ទើបក្រោយមកបានប៉ុន្មានឆ្នាំប៉ុណ្ណោះមេព្រៃក៏បានយកដីនោះដាំកូនឈើវិញ ។

លោក **យូរ ម៉ាលីន** មេរដ្ឋបាលព្រៃឈើស្រុករមាសហែកបានបង្ហើបថាដីនៅភូមិជីកដីនោះជាដីរបស់រដ្ឋស្ថិតក្នុងរង្វង់ ហ៊ុំព័ទ្ធស្ថានីយដាំឈើដែលបានដាំតាំងពីឆ្នាំ១៩៨៥ គឺដាំដើមអាកាស្យា និងដើមប្រេងខ្យល់ ។ លោកក៏បានបដិសេធថា ដីនោះរដ្ឋបាលព្រៃឈើមិនបានលក់ដូរទេ ក្រែងលោប្រជាពលរដ្ឋលក់ ឬអត់លក់ក៏លោកមិនបានដឹងដែរ ។

អ្នកស្រី **ងួន សូលីដា** អ្នកសំរបសំរួលសមាគមន៍អាដហុកនៅខេត្តស្វាយរៀងបានបញ្ជាក់បន្ថែមថា ករណីទំនាស់ដីធ្លីនោះយើងបានទទួលពាក្យបណ្តឹងពីប្រជាពលរដ្ឋហើយ ក៏បានចុះស៊ើបអង្កេតរឿងហ្នឹងដែរ ។ តាមព័តិមានដែរ អាដហុកទទួលបាន គឺប្រជាពលរដ្ឋបានកាន់កាប់ដីធ្លីធ្វើស្រែនោះធ្វើស្រែតាំងពីឆ្នាំ១៩៧៩ ។ ទើបក្រោយមកអាជ្ញាធរទៅដាំកូនឈើ

នៅលើដីស្រែរបស់ពួកគាត់ ។ ការប្រទាញប្រទង់គ្នារវាងប្រជាពលរដ្ឋ និងអាជ្ញាធររដ្ឋបាលព្រៃឈើ ធ្វើឱ្យអ្នកភូមិខកខានធ្វើស្រែចំការ ។ រហូតមកដល់ពេលនេះប្រជាពលរដ្ឋបានដាក់ពាក្យបណ្តឹងដល់រដ្ឋសភា ព្រឹទ្ធសភាហើយក្នុងនោះលោក **ជា ស៊ីម** ប្រធានព្រឹទ្ធសភា ក៏ចំណារឱ្យអាជ្ញាធរខេត្តធ្វើការដោះស្រាយ ប៉ុន្តែរហូតមកដល់ពេលនេះមិនមានការដោះស្រាយនោះទេ ។

អ្នកស្រី **ងួន សូលីដា** បានសង្កត់ធ្ងន់ថានៅឆ្នាំ ២០០៩ នេះស្ថានភាពទំនាស់ដីធ្លីមានសភាពធ្ងន់ធ្ងរជាងឆ្នាំ២០០៨ ពីព្រោះមានការចាប់ខ្លួនតំណាងប្រជាពលរដ្ឋ នៅស្រុកចន្រ្ទា ៣នាក់ ស្រុកស្វាយទាបចំនួន ២នាក់ ។ ទង្វើបែបនេះជាការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ ដោយសារបញ្ហាដីធ្លីសោះតែអាជ្ញាធរបានលើកហេតុផលជារឿងព្រហ្មទណ្ឌ ដើម្បីធ្វើការចោទប្រកាន់ចាប់ខ្លួនប្រជាពលរដ្ឋ ។

## សេចក្តីជូនដំណឹង

ចលនាយុវជនរបស់គណបក្សសិទ្ធិមនុស្ស មានកិត្តិយសសូមជំរាបជូនដំណឹងដល់យុវជន សិស្ស និស្សិត ព្រះសង្ឃ និងប្រជាពលរដ្ឋទាំងអស់អោយបានជ្រាបថា នៅទីស្នាក់ការកណ្តាលរបស់គណបក្សសិទ្ធិមនុស្សមានបើកវគ្គ បណ្តុះបណ្តាលលើមុខជំនាញមួយចំនួនដូចខាងក្រោម :

១. **ភាពជាអ្នកដឹកនាំ** សិក្សានៅរៀងរាល់ថ្ងៃសៅរ៍ ចាប់ពីម៉ោង៨:០០ព្រឹក ដល់ម៉ោង១១:៣០ថ្ងៃត្រង់ និង ពេលរសៀលចាប់ផ្តើមពីម៉ោង១:៣០ ដល់ម៉ោង ៤:៣០ល្ងាច ។

២. **វគ្គកុំព្យូទ័រ** Word Excel & Internet មាន៣ពេល ចាប់ពីម៉ោង១០ ដល់ម៉ោង១១ថ្ងៃត្រង់, ម៉ោង១១ ដល់ម៉ោង១២ថ្ងៃត្រង់ និងម៉ោង៣ ដល់ម៉ោង៤ល្ងាច ។

៣. ជំនាញបកប្រែកាសែតពីភាសាអង់គ្លេសទៅខ្មែរ ចាប់ផ្តើមនៅ ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៩ រៀងរាល់ថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រចាប់ពីម៉ោង១២ថ្ងៃត្រង់ ដល់ម៉ោង០១រសៀល ។

ចំពោះវគ្គសិក្សាទាំងអស់នេះ ប្រសិនបើយុវជន សិស្ស និស្សិត ព្រះសង្ឃ និងប្រជាពលរដ្ឋទាំងអស់ មានការចាប់អារម្មណ៍ សូមអញ្ជើញមកចុះឈ្មោះសិក្សា នៅទីស្នាក់ការកណ្តាលគណបក្សសិទ្ធិមនុស្ស ដែលមានអាស័យដ្ឋានផ្ទះលេខ៧២-៧៤ ផ្លូវ៥៩៨ សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ចាប់ទទួលចុះឈ្មោះចាប់ពីថ្ងៃ ជូនដំណឹងនេះតទៅចំនួនមានកំណត់ ។

សំរាប់ពត៌មានបន្ថែមទាក់ទងទូរស័ព្ទលេខ ០១៧ ៥០៣ ០០៧. ០១៧ ៩៩៥ ៤៥៤ ។

**បញ្ជាក់ :** ពេលបញ្ចប់វគ្គសិក្សានីមួយៗ សិស្ស និស្សិតទាំងអស់នឹងទទួលបានលិខិតបញ្ជាក់ការសិក្សាជូន ។ ដោយឡែកវគ្គសិក្សាភាពជាអ្នកដឹកនាំជំនាន់ទី១០ ចាប់ផ្តើមចូលរៀននៅថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០០៩ ។ ចំពោះសិក្ខាកាម ជាព្រះសង្ឃ អ្នករៀបចំកម្មវិធីនឹងទទួលចង្ហាន់ថ្ងៃត្រង់ ។

សូមអរគុណ !


| គ្រប់គ្រងការផ្សព្វផ្សាយ | | |
|---|---|---|
| លោក | ម៉ី សាន | ទូរស័ព្ទលេខ: ០១១ ៩០៤ ០៣១ |
| កញ្ញា | គង់ ចន្ទណ្ណា | ទូរស័ព្ទលេខ: ០១២ ៨៦៥ ២៥៥ |
| ផ្ទះលេខ៧២-៧៤,ផ្លូវលេខ៥៩៨, សង្កាត់បឹងកក់២,ខណ្ឌទួលគោក,ក្រុងភ្នំពេញ | | |


**សមាគមខ្មែរកម្ពុជាក្រោមស្នើបញ្ចូលថ្ងៃទី០៤ មិថុនា ជាថ្ងៃបុណ្យជាតិ !**